ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៧១ ប្រក.កសក

# ប្រកាស
## ស្តីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ របស់សមត្ថកិច្ចត្រួតតាមអនាម័យ

.......

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និង សេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ១៥អនក្រ.បកចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** បង្កើត នឹង កំណត់ ជាបណ្តោះអាសន្ន នូវឯកសណ្ឋាន នឹង សញ្ញាសម្គាល់សម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យភូតគាមអនាម័យ ឬ ចូលរួមក្នុងពិធីផ្លូវការផ្សេងៗ។

**ប្រការ ២ :** ឯកសណ្ឋានសម្រាប់សមត្ថកិច្ចភូតគាមអនាម័យក្នុងនេះមានខោ-អាវ និងមួកត្រូវផលិតដោយសាច់ក្រណាត់តេហ្គាលខ្សៀនពណ៌ស្លែចាស់ (សណ្តែកបាយ) ត្រូវកំណត់តាមតួនាទី និង ឋានៈ ដូចតទៅ :

**ក-ខោជើងវែង** ចំនួនពីរ ចង្កេះដេរតថ្មេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់គម្របរាងស្លឹកពោធិ៍ និង ហោប៉ៅពីរទៀតនៅ ចំហៀងដេរបង្កប់តាមថ្នេរ ។

**ខ-អាវមានពីរថ្នាក់:**

***-ថ្នាក់ដឹកនាំនាយកដ្ឋាននិងការិយាល័យ :***

អាវដៃខ្លី ចំនួនពីរ កបើក ប៉ូលស្មា នែកខ្នង មានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្តាលគម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង ឡេវមានរូបព្រះសង្ហារពណ៌មាស ។

***-ថ្នាក់មន្ត្រីនិងភ្នាក់ងារ :***

អាវដៃវែងមួយ អាវដៃខ្លីមួយ កឌុប ចោះឡេវចុងក ប៉ូលស្មា ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលគម្របរាងស្លឹកពោធិ៍ កាត់ស្រុងជើងត្រង់ដាក់ក្នុងខោ ។

**គ-មួកកាស្កេតមានបួនថ្នាក់:**

***-ថ្នាក់ដឹកនាំនាយកដ្ឋាន :*** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសប្រាំមួយទងពណ៌មាសទម្រង់ស្នែងក្របីចុងសងខាងដល់ជើងមួក ។ នៅលើកណ្តាប់វិណ្ណផ្នែកខាងមុខចំកណ្តាលរចនាដោយបាច់ផ្កាភ្ញីទេស និង អមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទំហំទទឹង ២០មិល្លីម៉ែត្រ ។

***-ថ្នាក់ការិយាល័យ :*** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសបួនទងពណ៌មាសទម្រង់ស្នែងក្របី ចុងសងខាងចន្លោះពីជើងមួក២០មិល្លីម៉ែត្រ ។

***-ថ្នាក់មន្ត្រីជាប្រធានភ្នាក់ការ :*** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសពីរទងពណ៌មាសទម្រង់ស្នែងក្របីចុងសងខាងចន្លោះពីជើងមួក៤០មិល្លីម៉ែត្រ ។

***-ថ្នាក់មន្ត្រីនិងភ្នាក់ងារ :*** លើជាយក្បាំងពណ៌ខ្មៅមានវិណ្ណទំហំ០៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធវង់ដល់ជើងមួក ។

**ឃ-ស្បែកជើងឃ្មុបពណ៌ខ្មៅ កខ្លី ស្រោមជើងពណ៌ខ្មៅ ។**

**ង - ខ្សែក្រវ៉ាត់ ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ។**

**ប្រការ ៣ :** ស្លាកសញ្ញាសម្គាល់សមត្ថកិច្ចភូតគាមអនាម័យត្រូវបានកំណត់សម្គាល់ដូចខាងក្រោម សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ ព្យួរលើឡេវគម្របហោប៉ៅឆ្វេងស្តាំ សម្រាប់សម្គាល់ឈ្មោះមន្ត្រីពាក់លើគម្របហោប៉ៅអាវខាងស្តាំ សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ ដូចខាងក្រោម :

**ក. ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ :** ធ្វើពីលោហធាតុដែលមានរាងមូលជាអឡ្យគោលដែលមានអង្កត់ផ្ចិត៣០មិល្លីម៉ែត្រលំអដោយក្រឡាសរសៃជាខ្សែរយៈបណ្តោយចំនួន៣ ខ្សែរយៈទទឹងចំនួន៣ និង ខ្សែរង្វង់ជុំវិញជាខ្សែភ្លោះ។ ក្រឡាសរសៃជាខ្សែរយៈបណ្តោយ ខ្សែរយៈទទឹង និង ខ្សែរង្វង់ជុំខាងក្នុងមានទទឹង១មិល្លីម៉ែត្ររាងត្រីកោណផ្កាប់។ ខ្សែរង្វង់ព័ទ្ធខាងក្រៅមានទទឹង១.៥មិល្លីម៉ែត្រមានរាងជាចំណិតផ្តៅផុសផ្កាប់ ។ នៅចំកណ្តាលពីលើអឡ្យគោលផ្នែកខាងក្នុងខ្សែរង្វង់ផុសមានលំអដោយរូបភាពផុសនៃពស់មានពិសយកកន្ទុយរុំព័ទ្ធគល់កួរស្រូវមួយកួរ និង ស្លឹកស្រូវមួយសន្លឹក ដោយចំកោងខ្លួនពីឆ្វេងទៅស្តាំ យកក្បាលគ្របប្រក់ពីលើកួរស្រូវនិងស្លឹកស្រូវសម្រាប់ដាក់លើចុងកអាវស្តាំ និង ពីស្តាំទៅឆ្វេងសម្រាប់ដាក់លើចុងកអាវឆ្វេង ។

**ខ. ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែរឹតម្របហោប៉ៅអាវស្តាំ :** មានរាងមូលប៉ោងធ្វើពីលោហធាតុមានអង្កត់ផ្ចិត៤៧មិល្លីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែកពណ៌ឈាមជ្រូកត្រូវបានកំណត់ដូចខាងក្រោម :

- ***ផ្នែកគែមជុំវិញ :*** មានខ្សែពណ៌ក្រហមដែលមានទទឹង ០១មិល្លីម៉ែត្រព័ទ្ធជុំវិញ
- ***ផ្នែកខាងលើ :*** មានប្រាសាទកំពូលបីពណ៌មាស
- ***ផ្នែកសងខាង :*** មានបាច់កួរស្រូវនៅខាងស្តាំ និង បាច់នៃពោត និង កប្បាសនៅខាងឆ្វេង ដែលបាច់ទាំងពីរផ្គុំគល់គ្នាជារង្វង់ស្នែងក្របី ដោយមានក្រណាត់ពណ៌ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា រុំព័ទ្ធខាងក្រោម និង រុំព័ទ្ធបាច់ទាំងពីរម្ខាងបីចំណង
- ***ផ្នែកខាងក្រោម :*** អក្សរកាត់ "**នគ្ស.កជក**" ពណ៌សនៅលើក្រណាត់ពណ៌ក្រហមនៃទង់ជាតិ ដែលរុំព័ទ្ធគុំបាច់នៃផលិតផលកសិកម្ម និង នៅខាងក្រោមក្រណាត់ពណ៌ទង់ជាតិនោះមានរូបភាពចំណិតកង់ស្តីពណ៌មាស ។
- ***ផ្នែកកណ្តាលស្លាក :*** ផ្ទៃជារង្វង់មូលមានពីរពណ៌ គឺពាក់កណ្តាលរង្វង់ខាងលើពណ៌ខៀវ និង ពាក់កណ្តាលរង្វង់ខាងក្រោមពណ៌បៃតងខ្ចី ។ ផ្ទៃនៃពាក់កណ្តាលរង្វង់ទាំងពីរត្រូវបានគូសចែកដោយខ្សែសន្ធារកាត់ផ្ចិតជាប្រាំ១ចំណែកស្មើគ្នា ដែលសណ្ឋានស្រដៀងគ្នាទៅនឹងសញ្ញាសម្គាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។
- ***នៅចំកណ្តាល :*** មានរូបពស់មានពិសពណ៌បៃតងចាស់យកកន្ទុយរុំព័ទ្ធគល់កួរស្រូវមួយកួរ និង ស្លឹកស្រូវមួយសន្លឹកនិងចំកោងក្បាលពីឆ្វេងទៅស្តាំប្រក់ព្រំការពារពីលើកួរស្រូវ ។
- ***នៅពីក្រោមខ្សែព្រំនៃផ្ទៃពណ៌បៃតងខ្ចីនិងពណ៌ខៀវ :*** មានអក្សរ "**ន.គ.ន**" ពណ៌ស ។

**គ. ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ :** ធ្វើអំពីជ័ររឹងមានផ្ទៃពណ៌ទឹកប៊ិកដែលមានទំហំទទឹង២០មិល្លីម៉ែត្រ បណ្តោយ១០០មិល្លីម៉ែត្រ កម្រាស់០២មីល្លីម៉ែត្រ។ នៅចំហៀងខាងឆ្វេងសញ្ញាសម្គាល់ឈ្មោះមានសញ្ញាសម្គាល់នាយកដ្ឋានក្សេត្រសាស្រ្ត និងកែលំអដីកសិកម្មទំហំ ១៥មិល្លីម៉ែត្រគុណនឹង១៥មិល្លីម៉ែត្រដែលស្ថិតនៅលើផ្ទៃពណ៌សទំហំ០២មិល្លីម៉ែត្រគុណនឹង២០មិល្លីម៉ែត្រ ។ នៅចំហៀងខាង

ស្លាកមានគូសខណ្ឌដោយបន្ទាត់ពណ៌មាសពាក់កណ្តាលស្របបណ្តោយផ្នែកខាងលើនៃបន្ទាត់បណ្តោយសរសេរឈ្មោះមន្ត្រីភូតគាមអនាម័យជាអក្សរខ្មែរ និង ផ្នែកខាងក្រោមសរសេរឈ្មោះជាអក្សរឡាតាំងពណ៌មាស ។

**ឃ-ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ :** ធ្វើពីក្រណាត់ដែលមានរាងមូលមានអង្កត់ផ្ចិត ៧០មិល្លីម៉ែត្រ ប៉ាក់នឹងអំបោះសូត្រ ត្រូវបានកំណត់ដូចខាងក្រោមៈ

- **ផ្នែកជុំវិញ :** ព័ទ្ធដោយពណ៌ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលខ្សែពណ៌ខៀវខាងក្រៅមានទទឹង ០២មិល្លីម៉ែត្រ ផ្ទៃឆ្នូតកណ្តាលពណ៌ក្រហម០៥មិល្លីម៉ែត្រ និង ខ្សែឆ្នូតខៀវខាងក្នុង០១មិល្លីម៉ែត្រ ។ នៅលើផ្នែកខាងលើនៃផ្ទៃជុំវិញនេះមានប៉ាក់អក្សរពណ៌លឿងថា "**មន្ត្រីភូតគាមអនាម័យ**" និងផ្នែកខាងក្រោមមានប៉ាក់អក្សរឡាតាំងពណ៌សថា "**PHYTOSANITARY OFFICER**" ។
- ផ្នែកកណ្តាល : នៅចំផ្ទៃកណ្តាល និង ជាផ្ទៃទ្រនាប់ក្រោមដែលមានអង្កត់ផ្ចិត៦២មិល្លីម៉ែត្រ មានពីរពណ៌ ដែលពាក់កណ្តាលរង្វង់ខាងក្រោមមានពណ៌បៃតងខ្ចី និង ពាក់កណ្តាលរង្វង់ខាងលើមាន ពណ៌ខៀវ ។
- **នៅលើផ្ទៃរង្វង់ទាំងពីរពណ៌ :** មានព័ទ្ធជុំវិញដោយខ្សែពណ៌សដែលមានកម្រាស់ ០១មិល្លីម៉ែត្រ និង លំអជាភូគោលដោយខ្សែពណ៌សដែលមានកម្រាស់០.៧មិល្លីម៉ែត្រ ជាខ្សែរយៈបណ្តោយ៣ខ្សែ និង ខ្សែរយៈទទឹង៣ខ្សែ ។
- **នៅលើកណ្តាលភូគោល :** មានប៉ាក់រូបពស់មានពិសពណ៌បៃតងចាស់ យកកន្ទុយរុំព័ទ្ធគល់កួរស្រូវមួយកួរ និង ស្លឹកស្រូវមួយសន្លឹក និង ចំកោងក្បាលពីឆ្វេងទៅស្តាំប្រកព្រំការពារពីលើកួរស្រូវ ។

**ប្រការ ៤ :** មន្ត្រីភូតគាមអនាម័យម្នាក់ៗមានសិទ្ធិទទួល នឹងប្រើប្រាស់ឯកសណ្ឋាន នឹងសញ្ញាសម្គាល់ដូចមានកំណត់ក្នុងប្រកាសនេះចំនួនពីរ(២)សម្រាប់ជារបបប្រចាំឆ្នាំ ។

**ប្រការ ៥ :** ក្នុងពេលបំពេញបេសកកម្ម សមត្ថកិច្ចភូតគាមអនាម័យត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងមានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន ។

**ប្រការ ៦ :** ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និង សញ្ញាសម្គាល់របស់សមត្ថកិច្ចភូតគាមអនាម័យត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ ៧ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៤

**រដ្ឋមន្ត្រី**

**ច័ន្ទ សារុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

# គំរូឯកសណ្ឋាន និងសញ្ញាសំគាល់របស់សមត្ថកិច្ចភូតគាមអនាម័យ




ស្លាកសញ្ញាសម្រាប់ពាក់លើចុងករអាវឆ្វេងស្តាំ




ស្លាកសញ្ញាសម្គាល់ឈ្មោះសម្រាប់ពាក់លើគំរបហោប៉ៅអាវស្តាំ



ស្លាកសញ្ញាសម្គាល់
សម្រាប់ព្យួរលើគំរបហោប៉ៅអាវស្តាំ




ស្លាកសញ្ញាសម្គាល់
សម្រាប់ដេរភ្ជាប់លើដើមដៃអាវស្តាំ